## ២ - សារាចរ

រាជធានីភ្នំពេញ , ថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ១៩៩៦

### សារាចរលេខ : ០៣ សរ

### ស្តីពីការធ្វើផ្លាកលេខយានយន្តគ្រប់ប្រភេទ

- យោងអនុក្រឹត្យលេខ ៣៤ អនក្រ ចុះថ្ងៃទី ១០/៩/១៩៨៩ ស្តីពីការផ្ទេរការងារចុះបញ្ជីបំណ្ណសំគាល់ផ្លាកលេខយានយន្ត បំណ្ណបើកបរ លិខិតអនុញ្ញាតធ្វើអាជីវកម្ម ការត្រួតពិនិត្យលក្ខណៈបច្ចេកទេស និង ការគ្រប់គ្រងយានជំនិះគ្រប់ប្រភេទ ពីក្រសួងមហាផ្ទៃ មកក្រសួងគមនាគមន៍ ដឹកជញ្ជូន និង ប្រៃសណីយ៍
- យោងស្មារតីរបស់អង្គប្រជុំអន្តរក្រសួង នៅថ្ងៃទី ២៦ ខែ តុលា ១៩៩៥ នៅទីស្តីការគណៈរដ្ឋមន្ត្រី ។
- ដើម្បីធានាបាននូវការឯកភាពជាទូទៅ ក្នុងការផ្តល់ផ្លាកលេខយានយន្តគ្រប់ប្រភេទ ក្នុងព្រះរាជាណាចក្រកម្ពុជា និង ដើម្បីងាយស្រួលក្នុងការគ្រប់គ្រងនូវមធ្យោបាយទាំងនោះ ដែលធ្វើចរាចរ និង ដឹកជញ្ជូនទំនិញគ្រប់ប្រភេទតាមផ្លូវសាធារណៈអោយមានប្រសិទ្ធភាព រាជរដ្ឋាភិបាលសូមធ្វើការណែនាំដូចខាងក្រោម ÷

១-មិនអនុញ្ញាតអោយរថយន្តឯកជន ទោះជាមានឋានៈណាក៏ដោយបានពាក់ផ្លាកលេខសញ្ញា «ខម» « នប » ឬ « មជ » ចាប់ពីពេលនេះតទៅ ។

២-ចំពោះរថយន្តរបស់ឯកជន ដែលក្រសួងការពារជាតិបានផ្តល់ផ្លាកលេខសញ្ញា « ខម » និង ក្រសួងមហាផ្ទៃបានផ្តល់ផ្លាកលេខ « នប » ឬ « មជ » កន្លងមកហើយ ម្ចាស់រថយន្តត្រូវទៅសុំប្តូរផ្លាកលេខស៊ីវិលនៅក្រសួងសាធារណការ និងដឹកជញ្ជូនមកប្រើប្រាស់ជំនួសវិញ ចាប់ពីថ្ងៃចេញសារាចររបស់រាជរដ្ឋាភិបាលនេះតទៅ ។

៣-ចំពោះមន្ត្រីយោធា នគរបាល ថ្នាក់ឧត្តមសេនីយ៍ ឬ វរសេនីយ៍ ដែលប្រើប្រាស់រថយន្តពាក់ផ្លាក លេខ ខម នប ឬ មជ ដោយពុំទាន់បង់ពន្ធនាំចូល ហើយពុំមានប្រាក់បង់ពន្ធនៅពេលទៅប្តូរយកផ្លាកលេខស៊ីវិល ក៏ប៉ុន្តែត្រូវការមធ្យោបាយជិះសំរាប់បំរើការ

ងារ រាជរដ្ឋាភិបាល និង ពិនិត្យពិចារណាលើការសុំរួចបន្ធូយពន្ធ ជូនដោយតំរូវអោយក្រសួងការពារជាតិ និង ក្រសួងមហាផ្ទៃលើកសំណើ ដើម្បីសុំបន្ថយពន្ធមករាជរដ្ឋាភិបាល ។ ប៉ុន្តែករណីនេះអាចធ្វើជូនបានចំពោះរថយន្តតែមួយគ្រឿងប៉ុណ្ណោះចំពោះមន្ត្រីយោធាឬ នគរបាលមួយនាក់ ដែលខូះខាតពិតប្រាកដហើយដែលរដ្ឋមន្ត្រីក្រសួងការពារជាតិ ក្រសួងមហាផ្ទៃទទួលស្គាល់ក្នុងបញ្ជីឈ្មោះដែលកំរិតយ៉ាងច្បាស់លាស់ ។ ក្រោយពីមានគោលការណ៍បន្ថយពន្ធពីរាជរដ្ឋាភិបាលហើយ រថយន្តខាងលើនេះត្រូវប្រើប្រាស់ផ្លាកលេខស៊ីវិលនៅ ក្រសួងសាធារណការ និង ដឹកជញ្ជូនវិញ ។

៤-លេខផ្លាកលេខ « ខម » អាចរក្សាទុកបានសំរាប់តែយានយន្តរបស់កងយោធពលខេមរភូមិន្ទដែលជាកម្មសិទ្ធិរបស់អង្គភាពកងយោធពលខេមរភូមិន្ទ ហើយផ្លាកលេខ« នប »សំរាប់តែយានយន្តរបស់នគរបាលជាតិ ដែលជាកម្មសិទ្ធិរបស់អង្គភាពនគរបាលជាតិតែប៉ុណ្ណោះ ពោលគឺពុំមែនជាយានយន្តរបស់បុគ្គល ហើយដែលមានលាបពណ៌ជាលក្ខណៈសំគាល់នៅលើយានយន្តពាក់លេខផ្លាកលេខ « ខម » ផ្លាកលេខ« នប » ទាំងនេះផង ។ ចំពោះរថយន្តផ្សេងទៀតរបស់ក្រសួងការពារជាតិ និង ក្រសួងមហាផ្ទៃ ដែលគ្មានលាបពណ៌ជាលក្ខណៈសំគាល់ គឺត្រូវប្រើផ្លាកលេខរាជការ ឬ រាជរដ្ឋាភិបាលដូចក្រសួងស្ថាប័ន នានា ។

៥-ក្រសួងការពារជាតិ និង ក្រសួងមហាផ្ទៃ ត្រូវបញ្ឈប់ការផ្តល់ផ្លាកលេខរថយន្ត « ខម » « នប » អោយរថយន្តឯកជនចាប់ពីពេលនេះតទៅ ហើយត្រូវរៀបចំនូវសញ្ញាផ្លាកលេខ « ខម » « នប » ជាថ្មីដោយមានលក្ខណៈសំគាល់ពិសេសមិនអាចក្លែងបន្លំបាន សំរាប់ប្រកាសអោយទទួលស្គាល់ និង ប្រើប្រាស់ទូទាំងប្រទេស ។

-ចំពោះរថយន្តដែលបានបង់ពន្ធរួចហើយ តែប្តូរលេខមិនទាន់ដោយហួសកាលបរិច្ឆេទ ដែលក្រសួងសាធារណការ និង ដឹកជញ្ជូនបានកំណត់ ក៏ត្រូវធ្វើស្ថិតិដោយឡែកដើម្បីដាក់ជូនរាជរដ្ឋាភិបាលពិនិត្យ និង សំរេច ។

៦-ចំពោះយានយន្តដែលគ្មានពាក់ផ្លាកលេខ ក្រសួងមានសមត្ថកិច្ចត្រូវចាប់ពិន័យអោយបានតឹងរឹង ចាប់ពីពេលដែលបានទទួលសារាចរនេះតទៅ ។

៧–ចំពោះរថយន្តដែលប្រើផ្លាកលេខរបស់រាជការ សាមីក្រសួងត្រូវទទួលខុសត្រូវផ្នែករដ្ឋប្បវេណីចេញសងនូវការខូចខាតដល់ជនរងគ្រោះ ប្រសិនបើមានគ្រោះថ្នាក់អ្វីមួយកើតឡើង ។ ប្រធានស្ថាប័ននីមួយ ៗ ត្រូវយកចិត្តទុកដាក់ត្រួតពិនិត្យ កុំអោយមានបញ្ហាយករថយន្តឯកជនពាក់ផ្លាកលេខ រាជការ ។

៨–ក្រសួងសាធារណការ និងដឹកជញ្ជូន ត្រូវសហការជាមួយក្រសួងមហាផ្ទៃអោយបានល្អ និង ទាន់ពេលវេលា នៅពេលដែលក្រសួងមហាផ្ទៃត្រូវការស្រាវជ្រាវលេខយានយន្តពាក់ព័ន្ធក្នុងការប្រព្រឹត្តិបទល្មើសអ្វីមួយ ។

៩–ក្រៅអំពីផ្លាកលេខ « ខម » ឬ « នប » ដែលមានលក្ខណៈកំណត់ក្នុងចំណុច ៤ និង ៥ ខាងលើនេះ ការកិច្ចចេញផ្លាកលេខឯទៀត ត្រូវប្រមូលផ្តុំនៅក្រសួងសាធារណការ និង ដឹកជញ្ជូន ។

១០–ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវរៀបចំគោលការណ៍មួយចំនួន ដើម្បីអោយអ្នកលក់យានយន្តគ្រប់ប្រភេទត្រូវតែបង់ពន្ធជាមុន ។ នឹងដាក់ចេញលក់នៅលើទីផ្សារក្នុងប្រទេស ។

ក្រោយពេលទទួលបានសារាចរនេះ រាជរដ្ឋាភិបាល សូមគ្រប់ក្រសួង ស្ថាប័នក្នុងព្រះរាជាណាចក្រកម្ពុជា យកចិត្តទុកដាក់អនុវត្តខ្លឹមសារនៃសារាចរនេះ អោយមានប្រសិទ្ធភាពខ្ពស់ ។

រាជរដ្ឋាភិបាលសង្ឃឹមជឿជាក់យ៉ាងមាំថា ក្រសួងការពារជាតិ ក្រសួងមហាផ្ទៃ និង ក្រសួងសាធារណការ និងដឹកជញ្ជូន ខិតខំយកចិត្តទុកដាក់ចាត់ចែង អនុវត្តតាមខ្លឹមសារសារាចរនេះប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ និង មានប្រសិទ្ធភាព ។

| | |
|---|---|
| នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី ២ |
| ព្រះហស្តលេខា និង ត្រា | ហត្ថលេខា និង ត្រា |
| **នរោត្តម រណឬទ្ធិ** | **ហ៊ុន សែន** |

* * *